**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ: ០៩៦ .សខល

ថ្ងៃអង្គារ ១៣រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**គោរពជូន**

**លោកជំទាវ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**កម្មវត្ថុ៖**ការអនុញ្ញាតឱ្យបើកដំណើរការនូវសារមន្ទីរនានាជូនភ្ញៀវជាតិ និងអន្តរជាតិបានចូលទស្សនាឡើងវិញ ចាប់ខែមិថុនា ឆ្នាំ២០២០ តទៅ។

**យោង៖** ចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** លើលិខិតលេខ ០៨៦ សខល ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់ក្រសួងសុខាភិបាល ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំ សូមជម្រាបជូនលោកជំទាវ រដ្ឋមន្ត្រី ជ្រាបថា ការចម្លងនៃវីរុសជំងឺកូវីដ-១៩ នៅទូទាំងពិភពលោកបានឈានដល់កម្រិតខ្ពស់ណាស់ គឺមានជាង ៤,៥លាននាក់ដែលឆ្លង និងមានករណីស្លាប់ជាង ៣០ម៉ឺននាក់ បើយោងទៅតាមការវាយតម្លៃហានិភ័យនៃការចម្លង និងរបាយការណ៍ដោយអង្គការសុខភាពពិភពលោក កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២០ នេះ។ ស្ថានភាពចម្លងនៅក្នុងតំបន់ ក៏នៅមិនទាន់មានការធូរស្បើយដែរ ដោយសារកំណើននៃការចម្លងវីរុសកូវីដ-១៩ និងការស្លាប់ដោយសារជំងឺនេះ នៅតែបន្តមាននៅឡើយ។

ដូច្នេះ ថ្វីត្បិតតែស្ថានភាពជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ មិនមានរកឃើញករណីឆ្លងថ្មីជាងមួយខែ អ្នកឈឺបានព្យាបាលជាសះស្បើយ ១០០% និងមិនមានករណីស្លាប់ក៏ពិតមែន ហើយភាគច្រើនលើសលុបសុទ្ធសឹងជាករណីនាំចូលមកពីក្រៅប្រទេស ក៏ប៉ុន្តែព្រះរាជាណាចក្រកម្ពុជា ត្រូវតែប្រកាន់យកការប្រុងប្រយ័ត្នជាប់ជានិច្ច ចំពោះការប្រឈមទៅនឹងការកើតមានឡើងនូវរលកទីពីរនៃការចម្លងវីរុសកូវីដ-១៩ ជាពិសេសការចម្លងនៅក្នុងសហគមន៍ ដែលអាចនឹងធ្វើឲ្យប៉ះពាល់ដល់នយោបាយ សុខភាពសាធារណៈ សេដ្ឋកិច្ច សង្គម និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជនទូទៅ ដែលពិបាកធ្វើការប៉ាន់ស្មានបាន។

គួរត្រូវកត់សម្គាល់ថា៖ វិធានការសុខភាពសាធារណៈចម្បងៗ ដែលបាន និងកំពុងអនុវត្តន៍នៅតាម បណ្តាប្រទេសក្នុងសកលលោក ដើម្បីទប់ស្កាត់ការឆាតត្បាតនៃវីរុសកូវីដ-១៩ រួមមានជាអាទិ៍ ការអនុវត្តអនាម័យដៃដោយលាងសម្អាតឲ្យបានញឹកញាប់ (Proper hand hygiene and washing) ការធ្វើចត្តាឡីស័ក (Quarantine) ចំនួន ១៤ថ្ងៃ ការដាក់ឱ្យនៅដាច់ដោយឡែក (Isolation) ការរក្សាគម្លាតសុវត្ថិភាពសង្គម (Social distancing) និងគម្លាតសុវត្ថិភាពបុគ្គល (Physical distancing) ជាដើម ។ល។ ដោយឡែក សម្រាប់ប្រទេសកម្ពុជា យុទ្ធសាស្ត្រចម្បងៗដើម្បីទប់ស្កាត់ការ

ភគត្បាតនៃវីរុសជំងឺកូវីដ-១៩ ដែលត្រូវបាន និងកំពុងអនុវត្តន៍ ហើយដែលនៅតែមានសុពលភាពអនុវត្តន៍នៅឡើយនោះ គឺ (១) ការរកឱ្យឃើញបុគ្គលទាំងឡាយណាដែលមានជំងឺកូវីដ-១៩ និងតាមរកបុគ្គលប៉ះពាល់អ្នកជំងឺនោះដោយផ្ទាល់ ឬដោយប្រយោលឱ្យបានរហ័ស (២) ការរាយការណ៍ឱ្យបានលឿនឆាប់រហ័ស (៣) ការដាក់ឱ្យនៅដាច់ដោយឡែកឱ្យបានឆាប់បំផុត និង (៤) ការផ្តល់ការព្យាបាលជាបន្ទាន់នៅក្នុងមន្ទីរពេទ្យរដ្ឋ។

ទន្ទឹមនឹងនោះ ដើម្បីចូលរួមទប់ស្កាត់រលកទីពីរនៃការចម្លងវីរុសកូវីដ-១៩នៅក្នុងប្រទេសកម្ពុជានិងបន្តចូលរួមការពារហានិភ័យនៃការចម្លងជំងឺកូវីដ-១៩ ព្រមទាំងកាត់បន្ថយផលប៉ះពាល់លើសេដ្ឋកិច្ច និងសង្គម សូមអនុវត្តនូវគោលការណ៍ណែនាំសំខាន់ៗដូចតទៅ៖

- យើងទាំងអស់គ្នា ត្រូវតែបន្តអនុវត្តន៍តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងយោងតាមស្មារតីអង្គប្រជុំ គណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ នាថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២០ ដោយមានចំណាប់ឯកភាពដ៏ខ្ពង់ខ្ពស់ពី **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ ក្រសួង សុខាភិបាល និងក្នុងនាមគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ សូមជម្រាបជូនលោកជំទាវរដ្ឋមន្ត្រីថា សារមន្ទីរនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានអនុញ្ញាតឲ្យបើកដំណើរការឡើងវិញ ដើម្បីជូនភ្ញៀវជាតិ និងអន្តរជាតិបានចូលទស្សនាចាប់ពីខែមិថុនា ឆ្នាំ២០២០ នេះតទៅ
- ទន្ទឹមនឹងនេះ ក្រសួងសុខាភិបាល សូមធ្វើការណែនាំជូនដល់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ថាមុនពេលបើកដំណើរការ ត្រូវរៀបចំវិធានការការពារនានាឲ្យរួចជាមុន ដើម្បីជៀសវាងនូវហានិភ័យនៃការចម្លងវីរុសកូវីដ-១៩ ដូចជាការស្កេនកំដៅភ្ញៀវមុនអនុញ្ញាតឲ្យចូលទស្សនា មានប្រើអាល់កុល ឬជែលលាងដៃ និងត្រូវរៀបចំឱ្យមានគម្លាតសុវត្ថិភាពបុគ្គល ព្រមទាំងត្រូវពាក់ម៉ាស់ ហើយត្រូវអនុវត្តឲ្យបានគ្រប់បុគ្គល (ទាំងភ្ញៀវ អ្នកនាំភ្ញៀវ និងអ្នកបម្រើការនៅទីនោះ) និងមិនត្រូវអនុញ្ញាតឱ្យភ្ញៀវ ឬបុគ្គលណាម្នាក់ដែលមានបញ្ហាសុខភាព ឬសង្ស័យចូលទស្សនាសារមន្ទីរឡើយ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកជំទាវរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងអនុវត្តន៍តាមការណែនាំខាងលើឲ្យមានប្រសិទ្ធិភាពខ្ពស់។

សូម **លោកជំទាវ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ** ទទួលនូវការគោរព និងរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

**ម៉ម ប៊ុនហេង**

__ចម្លងជូន៖__
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត
"ដើម្បីជូនជ្រាប និងសហការ"
-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល
"ដើម្បីមុខការ"
-ឯកសារ-កាលប្បវត្តិ



ទីស្តីការក្រសួងសុខាភិបាល អគារលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧៦